ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណរដ្ឋបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យរបស់ក្រសួងការពារជាតិមកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតម្លើងសាលាពេទ្យកងយោធពលខេមរភូមិន្ទ ទៅជាវិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ សរសេរកាត់ថា វ.វ.ស. ត្រូវបានសម្រេចប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងការពារជាតិ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ២.-

ទ.ទ.ស. ជានិតិបុគ្គល និងមានស្វ័យភាពហិរញ្ញវត្ថុ។

ទ.ទ.ស. មានអាសយដ្ឋាននៅភូមិព្រៃសណ្តែក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ ទ.ទ.ស.។

មាត្រា ៣.-

ទ.ទ.ស. មានភារកិច្ចដូចតទៅ ÷

-បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រវេជ្ជសាស្ត្រ ថ្នាក់វេជ្ជបណ្ឌិតទូទៅ ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រទន្តវេទនសាស្ត្រ ថ្នាក់ទន្តបណ្ឌិតទូទៅ ថ្នាក់បរិញ្ញាបត្រផ្នែកឱសថ ថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្ររង ផ្នែកគិលានុបដ្ឋាក ឆ្មបផ្នែកបច្ចេកទេសមន្ទីរពិសោធន៍ ផ្នែកជំនួយវេជ្ជសាស្ត្រ និងកម្មវិធីសិក្សាថ្នាក់ឆ្នាំមូលដ្ឋាន

-បណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសិក្សា

-រៀបចំ និងដំណើរការការងារប្រឡងជ្រើសរើសសិស្ស និស្សិតជាគងទ័ពនិងស៊ីវិលឱ្យចូលរៀនវគ្គអាហារូបករណ៍ និងវគ្គបង់ថ្លៃ

-ធ្វើក្រឹតការអ្នកបច្ចេកទេសស្របតាមសំណូមពរសេចក្តីត្រូវការរបស់ក្រសួងការពារជាតិ

-បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់មហាវិទ្យាល័យវេជ្ជសាស្ត្រ និងសម្រាប់សាលាថែទាំវេជ្ជសាស្ត្រ

-រៀបចំកម្មវិធីសិក្សាដោយមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងដោយមានការឯកភាពពីក្រសួងការពារជាតិ

-រៀបចំស្រាវជ្រាវវិទ្យាសាស្ត្រវេជ្ជសាស្ត្រ ឱសថសាស្ត្រទន្តវេទនសាស្ត្រ វិទ្យាសាស្ត្រថែទាំ

-សិក្សាស្រាវជ្រាវកម្មវិធីសិក្សា ខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀន ចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាខ្មែរ និងភាសាបរទេស ស្របតាមតម្រូវការប្រើប្រាស់ និងសម្រាប់ផ្សព្វផ្សាយទូទៅ

-កសាងផែនការមូលដ្ឋានសម្ភារៈសម្រាប់ ទ.ទ.ស.

-គ្រប់គ្រងនាយទាហាន នាយទាហានរង បុគ្គលិក កម្មករ និស្សិត សិស្ស សាស្ត្រាចារ្យ វេជ្ជបណ្ឌិត និងទ្រព្យសម្បត្តិរបស់ ទ.ទ.ស.

-ទំនាក់ទំនងសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានា ធ្វើឱ្យកាន់តែល្អប្រសើរនូវការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស។

## ជំពូកទី២
## ការដឹកនាំនិងការគ្រប់គ្រង
### ផ្នែកទី១
### ក្រុមប្រឹក្សាភិបាល

មាត្រា ៤.-

ទ.ទ.ស. ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិយ៉ាងទូលំទូលាយ ដើម្បីចាត់ចែងការងារក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ ទ.ទ.ស. ។

មាត្រា ៥.-

៥.១. ក្រុមប្រឹក្សាភិបាល មានសមាជិក ០៧(ប្រាំពីរ) រូប ដែលមានសមាសភាពដូចតទៅ ÷

| | |
|---|---|
| -តំណាងក្រសួងការពារជាតិ | ប្រធាន |
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -តំណាងក្រសួងសុខាភិបាល | សមាជិក |
| -តំណាងក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| -នាយក ទ.ទ.ស. | សមាជិកស្វ័យប្រវត្តិ |
| -តំណាងបុគ្គលិក ទ.ទ.ស. | សមាជិកស្វ័យប្រវត្តិ។ |

៥.២. តំណាងបុគ្គលិក ទ.ទ.ស. ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក ទ.ទ.ស. សម្រាប់អាណត្តិនីមួយៗ។

៥.៣. ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវបានតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ (បី) ឆ្នាំ និងអាចបន្តបានទៀតតាមសំណើរបស់ក្រសួង ឬស្ថាប័នដែលខ្លួនតំណាងឱ្យ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលាដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬស្ថាប័នដែលខ្លួនតំណាងឱ្យ។

មាត្រា ៦.-

សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្មធ្លាប់បានបម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានបទពិសោធគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យវិទ្យាសាស្ត្រសុខាភិបាល សេដ្ឋកិច្ច អប់រំ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមានលិខិតថ្កោលទោសបញ្ជាក់ថាពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈឹម ឬបទឧក្រិដ្ឋពីតុលាការឡើយ។

មាត្រា ៧.-

៧.១.ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

៧.២.ក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជននៅក្រៅ ក្រុមប្រឹក្សាភិបាលដែលមានបទពិសោធលើវិស័យវិទ្យាសាស្ត្រសុខាភិបាល និងតំណាងដៃគូអភិវឌ្ឍចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

មាត្រា ៨.-

ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំតម្រង់ទិសដៅ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ ទ.ទ.ស.។ ក្នុងក្របខណ្ឌនៃបេសកកម្មនេះក្រុមប្រឹក្សាភិបាលត្រូវ ៖

-ពិនិត្យ និងសម្រេចលើគំរោងផែនការអភិវឌ្ឍនៃ ទ.ទ.ស. ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
-ពិនិត្យនិងសម្រេចលើគម្រោងផែនការសកម្មភាពនៃ ទ.ទ.ស.
-ពិនិត្យនិងសម្រេចលើចំណូលនិងចំណាយប្រចាំឆ្នាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ ទ.ទ.ស.
-ពិនិត្យនិងសម្រេចលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
-កំណត់ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចដល់គ្រប់ការិយាល័យ និងអង្គភាពក្រោមឱវាទ និងធ្វើការអភិវឌ្ឍតាមការចាំបាច់របស់ ទ.ទ.ស.
- កំណត់បែបបទនៃការជ្រើសរើស ការដំឡើងឋានន្តរសក្តិ ការផ្តល់លាភសការដល់បុគ្គលិក ទ.ទ.ស. ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះមន្ត្រីមុខងារសាធារណៈ
-សម្រេចលើក្របខណ្ឌចំនួនបុគ្គលិកដែលអនុញ្ញាតសម្រាប់ ទ.ទ.ស.
-សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្មសាធារណៈដោយអនុវត្តតាមបទបប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ
-កែសម្រួលបទបញ្ជាផ្ទៃក្នុង ទ.ទ.ស. ដោយមានការយល់ព្រមពីប្រធានស្ថាប័ន ឬក្រសួងអាណាព្យាបាលទាំងពីរ
-វាយតម្លៃតាមចន្លោះពេលទៀងទាត់លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ ទ.ទ.ស. ហើយកំណត់នូវវិធានការកែតម្រូវ ដើម្បីអនុវត្ត។

មាត្រា ៩.-

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងការពារជាតិ។

មាត្រា ១០.-

១០.១.ក្រុមប្រឹក្សាភិបាល ទ.ទ.ស. ត្រូវធ្វើការប្រជុំយ៉ាងតិច៣(បី)ខែម្តង តាមគំនិតផ្តួចផ្តើម និងការអញ្ជើញរបស់ប្រធានឬតាមការស្នើរបស់សមាជិក ២/៣ (ពីរភាគបី) ឡើងទៅឬតាមការស្នើសុំរបស់នាយក ទ.ទ.ស.។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលដើម្បីដឹកនាំការប្រជុំ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការអង្គប្រជុំ១(មួយ)រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ។ របៀបវារៈព្រមទាំងឯកសារទាំងឡាយត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច ១០(ដប់) ថ្ងៃ មុនថ្ងៃប្រជុំ។

១០.២. ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចនិងយកជាការបាន លុះត្រាមានសមាជិកវត្តមានចំនួនលើសពី ៥០(ហាសិប) ភាគរយនៃសមាជិកទាំងអស់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសបានឡើយ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ)ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញប្រជុំលើកមុន។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំ ចាត់ទុកជា ឧត្តមានុភាព ។

១០.៣. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ និងតំកល់ទុកនៅទីស្នាក់ការ ទ.ទ.ស. និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ។ កំណត់ហេតុនេះត្រូវបង្ហាញអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ ១០(ដប់)ថ្ងៃ ក្រោយពេលប្រជុំ។

១០.៤. ទ.ទ.ស. ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ ៖

-កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

-ផែនការអភិវឌ្ឍរបស់ ទ.ទ.ស.

-គម្រោងថវិកាប្រចាំឆ្នាំ

-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

១០.៥. ឯកសារទាំងនេះត្រូវបញ្ជូនទៅអ្នកដែលទទួលក្នុងរយៈពេលមិនឱ្យហួសពី១៥ (ដប់ប្រាំ) ថ្ងៃឡើយ។

## ផ្នែកទី២
## អង្គភាពប្រតិបត្តិ នៃវិទ្យាស្ថាន

មាត្រា ១១.-

 វ.វ.ស. ត្រូវគ្រប់គ្រងដោយនាយកវិទ្យាស្ថានមួយរូប ដែលមានឋានៈស្មើអគ្គនាយក។ នាយក វ.វ.ស. មានតួនាទីជានាយកប្រតិបត្តិ។

មាត្រា ១២.-

១២.១.នាយក វ.វ.ស.មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រងនិងអនុវត្តការងារ ដែលមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល។

នាយក វ.វ.ស. មានភារកិច្ចដូចតទៅ ÷

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការនូវគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ វ.វ.ស.ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច
- ធ្វើរបាយការណ៍គ្រប់គ្រង ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់លើភារកិច្ចរបស់បណ្ណាការិយាល័យ និងអង្គភាពក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ វ.វ.ស. ក្នុងការកម្រិតក្របខណ្ឌចំនួនបុគ្គលិកដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពវិធានស្តីពីការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ វ.វ.ស. ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកសិទ្ធិអំណាចនិងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត។

១២.២. នាយក វ.វ.ស. ជាតំណាងរបស់វិទ្យាស្ថាន ក្នុងការទំនាក់ទំនងជាមួយតតិយជន។

១២.៣. នាយក វ.វ.ស.ត្រូវស្នើទៅក្រសួងការពារជាតិ សុំតែងតាំងនាយករងមួយរូប ឬច្រើនរូប មានឋានៈស្មើប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។

## ផ្នែកទី៣
## បុគ្គលិករបស់ វ.វ.ស.

មាត្រា ១៣.-

១៣.១. បុគ្គលិកអចិន្ត្រៃយ៍របស់ វ.វ.ស. រួមមានមន្ត្រីក្របខណ្ឌមកពីក្រសួងការពារជាតិ និងមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈមកពីក្រសួងស្ថាប័នដទៃទៀត។ មន្ត្រីទាំងនេះត្រូវបានរក្សាទុកនូវក្របខណ្ឌប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

១៣.២. វ.វ.ស. អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជំនួយការ និងបុគ្គលិកអណ្តែត។ បុគ្គលិកទាំងនោះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ។

១៣.៣. បុគ្គលិក មន្ត្រីរាជការ វ.វ.ស. ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីការគ្រប់គ្រងបុគ្គលិកដែលបានសម្រេចដោយក្រុមប្រឹក្សាភិបាល។ បទបញ្ជាស្តីពីបុគ្គលិកនេះ មិនត្រូវផ្ទុយពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិកព្រមទាំងបែបបទនៃការទូទាត់ផង ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

## ផ្នែកទី៤
## ទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន

មាត្រា ១៤.-

១៤.១. វ.វ.ស. ទទួលដើមទុនដំបូងពីរដ្ឋជាដីធ្លីនិងអចលនវត្ថុ ដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធតាមឯកសារពីកណ្តូចុងក្រោយ ដែលផ្ទៃដីមានប្រមាណ ៨០ ០០០ (ប៉ែតសិបពាន់) ម៉ែត្រក្រឡា ដែលមានអាសយដ្ឋានស្ថិតនៅភូមិព្រៃសណ្តែក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

១៤.២. វ.វ.ស.អាចទិញ ប្តូរ ឬលក់ចលនទ្រព្យ អចលនទ្រព្យចាំបាច់សម្រាប់ដំណើរការរបស់វិទ្យាស្ថានដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន។

## ផ្នែកទី៥

## ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់ ទ.ទ.ស.

**មាត្រា ១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យនៃ ទ.ទ.ស. ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ។

**មាត្រា ១៦.-**

១៦.១. នាយក ទ.ទ.ស. ជាអាណាប័កដើមខ្សែរបស់វិទ្យាស្ថាន ហើយត្រូវមានភារកិច្ចដូចតទៅ ៖

-ពិនិត្យប្រាក់ និងទូទាត់ចំណូល

-ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ។

១៦.២.អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិឬអាចបង្កើតនូវរជ្ជទេយ្យចំណូលឬបុរេប្រទានបាន ដោយ មានការព្រមព្រៀងពីគណនេយ្យករ ទ.ទ.ស.។

**មាត្រា ១៧.-**

១៧.១. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ ទ.ទ.ស. ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករនេះត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។ គណនេយ្យករនេះត្រូវទទួលខុសត្រូវចំពោះមុខនាយក ទ.ទ.ស. និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែឥតមានសំឡេងឆ្នោតឡើយ។

១៧.២. គណនេយ្យករមានភារកិច្ចដូចតទៅ ៖

-ប្រមូលចំណូល

-បើកប្រាក់ចំណាយ

-ថែរក្សានិងចាត់ចែងប្រើប្រាស់នូវមូលនិធិនិងធនធានរបស់ ទ.ទ.ស.

-ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ។

១៧.៣. គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុការីរបស់ខ្លួន។

មាត្រា ១៨.-

១៨.១. ប្រភពធនធានរបស់ ទ.ទ.ស. រួមមាន ÷

-ធនធានដែលរដ្ឋផ្ដល់ដល់ ទ.ទ.ស. នៅពេលផ្ដើមបង្កើតដំបូង

-ឧបត្ថម្ភធនសម្រាប់ដំណើរការនិងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ

-អំណោយ ជំនួយ និងអច្ច័យទានដែល ទ.ទ.ស. បានទទួល

-ប្រាក់ខ្ចីបុលដោយផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ ទ.ទ.ស.

-ផលការងារ និងកម្រៃ នៃការផ្ដល់សេវាផ្សេងៗដោយ ទ.ទ.ស.

-កម្រៃនៃទ្រព្យរបស់ ទ.ទ.ស. និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល

-កម្រៃដែលបានមកពីការបង់ថ្លៃសិក្សារបស់សិស្ស និស្សិត

-កម្រៃនៃទ្រព្យសម្បត្តិ ដែលបានប្រគល់ឱ្យ ទ.ទ.ស. ។

១៨.២. ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ ទ.ទ.ស. ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ ទ.ទ.ស.។ ក្រុមប្រឹក្សាភិបាលរបស់ ទ.ទ.ស. ត្រូវកំណត់អំពីបែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកា។ សេចក្ដីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ទាក់ទងដល់ទម្រង់បែបបទនៃការរៀបចំការចាត់ចែង និងអនុវត្តថវិកាត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៨.៣. ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ ទ.ទ.ស. ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូលនិងចំណាយ។

១៨.៤. អនុលោមតាមមាត្រា ១៣ នៃអនុក្រឹត្យនេះ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗនៃមន្ត្រីរាជការគ្រប់ខណ្ឌមុខងារសាធារណៈដែលមកបម្រើការងារក្នុង ទ.ទ.ស. ជាបន្ទុកនៃថវិការដ្ឋ។

១៨.៥. ប្រាក់ឧបត្ថម្ភរបស់រដ្ឋដែលបានគ្រោងទុកក្នុងថវិកាជាតិ ដើម្បីផ្ដល់ឱ្យ ទ.ទ.ស. ត្រូវសំដៅជាពិសេសលើចំណាយថ្លៃទឹកនិងថ្លៃភ្លើង។

១៨.៦.សោហ៊ុយវិភាគនិងសោហ៊ុយដំណើរការសម្រាប់ស្រាវជ្រាវវិភាគ សម្រាប់ពេលមានភាពអាសន្ន ត្រូវចែងក្នុងកិច្ចសន្យាមួយរវាងរដ្ឋ និង ទ.ទ.ស. ដែលមានបញ្ជាក់ចំណែកដែលម្ខាងៗត្រូវរ៉ាប់រង។

មាត្រា ១៩.-

១៩.១. ការងារគណនេយ្យរបស់ ទ.ទ.ស. រួមមាន ÷

-គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេរភាគដែលចែងអំពីប្រតិបត្តិការថវិការតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន

-គណនេយ្យអសង្ហារិម រូបធាតុ និងគណនេយ្យតម្លៃ

-គណនេយ្យវិភាគប្រសិនបើជាការចាំបាច់ ។

គណនេយ្យរបស់ ទ.ទ.ស. ត្រូវ ៖

-ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-គោរពតាមប្លង់គណនេយ្យរបស់ ទ.ទ.ស.ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ប្លង់គណនេយ្យនេះត្រូវបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៩.២.របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ ទ.ទ.ស. ត្រូវរៀបចំដោយគណនេយ្យករ និងអាណាប័កដើមខ្សែ ដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាល ពិនិត្យនិងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣(បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។

មាត្រា ២០.-

មូលនិធិរបស់ ទ.ទ.ស. គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនេយ្យមួយនៅរតនាគារជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ផ្នែកទី៦

## របបសារពើពន្ធនៃ ទ.ទ.ស.

មាត្រា ២១.-

លើកលែងតែមានបដិប្បញ្ញត្តិ ដែលចែងដោយច្បាប់ ទ.ទ.ស. ត្រូវស្ថិតនៅក្រោមនីតិរួមចំពោះរបបសារពើពន្ធ។

## ផ្នែកទី៧

## លទ្ធកម្មរបស់ ទ.ទ.ស.

មាត្រា ២២.-

ការសម្រេចការអនុវត្ត និងការត្រួតពិនិត្យលើលទ្ធកម្មរបស់ ទ.ទ.ស.ត្រូវគ្រប់គ្រងតាមច្បាប់ និងបទបញ្ញត្តិជាធរមានទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហានេះ។

ជំពូកទី៣

ផ្នែកទី១

អាណាព្យាបាលបច្ចេកទេស

មាត្រា ២៣.-

២៣.១. ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល នាយក ទ.ទ.ស. ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍនិងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល១(មួយ)ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ដើម្បីរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមានរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃបានទទួលឯកសារដែលបានបញ្ជូនដោយនាយក ទ.ទ.ស. ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនោះ។

២៣.២. លិខិតយល់ព្រមត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងការពារជាតិឬតំណាង ហើយត្រូវផ្ញើជូនទៅនាយក ទ.ទ.ស. ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នាយក ទ.ទ.ស. ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីរដ្ឋមន្ត្រីក្រសួងការពារជាតិ មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍឬគម្រោងថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាព។ ប្រសិនបើរដ្ឋមន្ត្រីក្រសួងការពារជាតិ ធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សានិងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ។

កម្មវិធីអភិវឌ្ឍនៃ ទ.ទ.ស. និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងការពារជាតិ ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំប្រព័ន្ធម៉ីរបកជា ១២ (ដប់ពីរ)ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ។

មាត្រា ២៤.-

២៤.១ រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចមានយោបល់ជំទាស់លើឯកសារ ដែលបានបញ្ជូនមកខ្លួនដូចមានចែងក្នុងមាត្រា ១០ ចំណុច ១០.៤ នៃអនុក្រឹត្យនេះ មានកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងការពារជាតិ មានរយៈពេល ១ (មួយ)ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ។

២៤.២ នាយក ទ.ទ.ស. ត្រូវជូនព័ត៌មានដល់ក្រុមប្រឹក្សាភិបាលអំពីខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និងវិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាបានការនូវការជំទាស់ទាំងនេះ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជាបន្ទាន់ភ្លាមនូវដំណឹងអំពីបញ្ហានេះជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ។

មាត្រា ២៥.-

២៥.១. រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចលុបឬផ្អាកទុកនូវសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល ឬនាយក ទ.ទ.ស. ក្នុងករណីដែលសេចក្ដីសម្រេចនោះ ÷

- ផ្ទុយនឹងគោលដៅរបស់វិទ្យាស្ថាន
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ធ្វើឡើងដោយអាជ្ញាធរមួយដែលពុំមានសិទ្ធិសម្រេច ឬធ្វើឡើងដោយការប្រជុំពុំស្របច្បាប់របស់ក្រុមប្រឹក្សាភិបាល។

២៥.២. ការលុបចោលឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួនឬតាមបណ្ដឹងពីភាគីនានាដែលពាក់ព័ន្ធ។ ការលុបចោល ឬការផ្អាកទុកនូវសេចក្ដីសម្រេចនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយក ទ.ទ.ស. ហើយនាយក ទ.ទ.ស. ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលយ៉ាងឆាប់បំផុត។

មាត្រា ២៦.-

រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចចាត់ឱ្យធ្វើអធិការកិច្ចឬការត្រួតពិនិត្យការងាររបស់ ទ.ទ.ស. ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី២

## អាណាព្យាបាលហិរញ្ញវត្ថុ

មាត្រា ២៧.-

២៧.១. ក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាលនាយក ទ.ទ.ស. ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការពារជាតិ។ រដ្ឋមន្ត្រីក្រសួងការពារជាតិ មានរយៈពេល ១(មួយ)ខែ គឺចាប់ពីថ្ងៃទទួលឯកសារដើម្បីផ្ដល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល២(ពីរ)ខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមក ដោយនាយក ទ.ទ.ស.ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

២៧.២.លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឬអ្នកតំណាង ត្រូវផ្ញើទៅនាយក ទ.ទ.ស. ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ។ នាយក ទ.ទ.ស.ត្រូវជូនព័ត៌មាននេះដល់ក្រុមប្រឹក្សាភិបាល យ៉ាងឆាប់បំផុត។

ក្នុងករណីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ។ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយក្នុងករណីដែលការជំទាស់ដែលលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំត្រូវបានដោះស្រាយនៅឡើយនោះ។

មាត្រា ២៨.-

សេចក្តីសម្រេចដូចបានរៀបរាប់ខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាលឬនាយក ទ.ទ.ស.ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការពារជាតិ តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន÷

-សេចក្តីសម្រេចស្តីពីការលក់ ឬការផ្ទេរសិទ្ធិអចលនទ្រព្យ

-សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់និងកិច្ចព្រមព្រៀងសម្រាប់ការធានាឬលិខិតស្រដៀងគ្នានេះ។

សេចក្តីសម្រេចនេះត្រូវអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិជាធរមាន។

មាត្រា ២៩.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មួយរូបប្រចាំ ទ.ទ.ស.។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើ ទ.ទ.ស. ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មាត្រា ៣០.-

៣០.១. ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែ ទ.ទ.ស. ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣០.២. ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាល នៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣០.៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់អធិការកិច្ច ឬការត្រួតពិនិត្យលើ ទ.ទ.ស. នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៤៦/

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាប
ជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
សូមហត្ថលេខា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

ទៀ បាញ់

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ